អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា
United Nations in Cambodia

# ក្រុម អ.ស.ប ប្រចាំប្រទេសកម្ពុជា
# ជំហរស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀន និង
# ការគាំទ្រដល់រាជរដ្ឋាភិបាលកម្ពុជា
# ថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០១០

---

១. ការញៀនគ្រឿងញៀនគឺជាជម្ងឺមួយដែលអាចបង្ការ និងព្យាបាលបាន ហើយការបង្ការដ៏មានប្រសិទ្ធភាពនិងកិច្ចអន្តរាគមន៍ព្យាបាលអាចមាន។ លទ្ធផលប្រសើរបំផុត អាចនឹងសម្រេចបាននៅពេលដែលមានវិធីសាស្ត្រទូទៅមួយបែបពហុវិស័យ រាប់ទាំងកិច្ចអន្តរាគមន៍ចម្រុះផ្អែកឱសថសាស្ត្រ និងចិត្តសង្គម ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការផ្សេងៗ។

២. ជំហរបស់អង្គការសហប្រជាជាតិប្រចាំប្រទេសកម្ពុជា (UNCT) និងសកម្មភាពស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀន ត្រូវបានចង្អុលបង្ហាញដោយគោលការណ៍របស់អង្គការ UNODC-WHO ស្តីពីការព្យាបាលអ្នកញៀនគ្រឿងញៀន ដែលបានបោះពុម្ពផ្សាយនៅខែមីនា ឆ្នាំ២០០៨។ គោលការណ៍ទាំងនេះ ត្រូវបានប្រើប្រាស់នៅក្នុងកិច្ចពិភាក្សាជាមួយរដ្ឋាភិបាលនានានៅទូទាំងពិភពលោក ចាប់តាំងពីការចេញផ្សាយគោលការណ៍នេះមក។

៣. គោលការណ៍ទី៣ និងទី៤ ទាក់ទងជាពិសេសទៅនឹងស្ថានភាពបច្ចុប្បន្ននៅប្រទេសកម្ពុជា។ **គោលការណ៍ទី៣៖** ការព្យាបាលអ្នកញៀនគ្រឿងញៀនផ្អែកលើព័ត៌មានភស្តុតាង ។ "ការអនុវត្តល្អផ្អែកលើភស្តុតាង និងចំណេះដឹង បែបវិទ្យាសាស្ត្រដែលប្រមូលបានស្តីពីចរិតលក្ខណៈនៃការញៀនគ្រឿងញៀន អាចចង្អុលបង្ហាញដល់កិច្ចអន្តរាគមន៍ និងការវិនិយោគក្នុងការព្យាបាលអ្នកញៀនគ្រឿងញៀន។ គុណភាពខ្ពស់នៃបទដ្ឋានដែលតម្រូវសម្រាប់ការអនុម័តយល់ព្រមលើកិច្ចអន្តរាគមន៍ផ្អែកឱសថសាស្ត្រ ឬចិត្តសាស្ត្រ នៅក្នុងគ្រប់វិស័យវេជ្ជសាស្ត្រផ្សេងទៀត គួរតែត្រូវបានអនុវត្តចំពោះវិស័យនៃការញៀនគ្រឿងញៀនផងដែរ"។

៤. **គោលការណ៍ទី៤៖** ការព្យាបាលអ្នកញៀនគ្រឿងញៀន សិទ្ធិមនុស្ស និងសេចក្តីថ្លៃថ្នូររបស់អ្នកជម្ងឺ។ "សេវាព្យាបាលអ្នកញៀនគ្រឿងញៀន គួរតែគោរពតាមកាតព្វកិច្ចសិទ្ធិមនុស្ស និងទទួលស្គាល់សេចក្តីថ្លៃថ្នូរដែលមានជាប់ពីកំណើតរបស់បុគ្គលទាំងអស់។ នេះរាប់ទាំងការឆ្លើយតបទៅនឹងសិទ្ធិទទួលបានបទដ្ឋានខ្ពស់បំផុតខាងសុខភាព និងសុខុមាលភាព និងធានាមិនឲ្យមានការរើសអើង"។ នៅក្នុងចំណោមសមាសធាតុទាំងឡាយក្នុងគោលការណ៍នោះ យើងសូមរំលេចពីរចំណុច៖

ក. ដូចគ្នាទៅនឹងនីតិវិធីវេជ្ជសាស្ត្រដទៃទៀតដែរ ក្នុងលក្ខខណ្ឌទូទៅ ការព្យាបាលអ្នកញៀនគ្រឿងញៀន ទោះជាតាមបែបចិត្តសង្គម ឬឱសថសាស្ត្រក្តី - ក៏មិនគួរធ្វើដោយបង្ខំទៅលើអ្នកជម្ងឺឡើយ។ លុះត្រាតែក្នុងស្ថានភាពវិបត្តិពិសេសដែលមានហានិភ័យខ្ពស់ចំពោះខ្លួនឯង ឬចំពោះអ្នកដទៃប៉ុណ្ណោះ ដែលការព្យាបាលចាំបាច់ត្រូវធ្វើដោយខានមិនបានសម្រាប់លក្ខខណ្ឌជាក់លាក់ និងនៅក្នុងអំឡុងពេលមួយដែលច្បាប់បានកំណត់។

ខ. ក្នុងករណីដែលការប្រើប្រាស់ និងការកាន់កាប់គ្រឿងញៀន ដែលនាំដល់ការដាក់ទោសព្រហ្មទណ្ឌដោយរដ្ឋមួយ ជម្រើសនៃការព្យាបាលត្រូវបង្ហាញប្រាប់អ្នកជម្ងឺ ឬជនល្មើស ជាជំនួសឲ្យការដាក់ពន្ធនាគារ ឬទោសព្រហ្មទណ្ឌការផ្សេងទៀត។ ជម្រើសនេះ អ្នកជម្ងឺ ឬជនល្មើស គឺជាអ្នកសម្រេច។

៥. **គោលការណ៍ទី៥៖** ផ្តោតគោលដៅលើលក្ខខណ្ឌ និងអនុក្រុមពិសេស។ ស្របតាមគោលការណ៍ទាំងនេះ វិធីសាស្ត្រដែលជាគោលដៅនិងផ្សេងៗគ្នា ត្រូវបានដាក់ស្នើជាអនុសាសន៍ នៅពេលដោះស្រាយសេចក្តីត្រូវការជាក់លាក់របស់ក្រុមមនុស្សមួយចំនួន ដូចជា កុមារ យុវវ័យ និងស្ត្រី។

៦. ក្នុងខែមីនា ឆ្នាំ២០១៩ អង្គការ UNODC រួមគ្នាជាមួយអង្គការសុខភាពពិភពលោក WHO បានចាប់ផ្តើមកម្មវិធីរួមមួយស្តីពីការព្យាបាល និងការថែទាំអ្នកញៀនគ្រឿងញៀន ដោយមានទស្សនៈវិស័យមួយនៃប្រព្រឹត្តកម្មប្រកបដោយប្រសិទ្ធភាព និងមនុស្សធម៌ចំពោះមនុស្សទាំងអស់ដែលមានបញ្ហាញៀនគ្រឿងញៀន ដែលមិនតិចជាងអ្វីដែលគេរំពឹងសម្រាប់ជម្ងឺដទៃផ្សេងទៀតឡើយ។

៧. កម្មវិធីរួមគ្នារបស់អង្គការ UNODC / WHO លើកកម្ពស់គោលនយោបាយ ដែលធ្វើឲ្យមានតុល្យភាពគ្នារវាងការកាត់បន្ថយការផ្គត់ផ្គង់គ្រឿងញៀន និងសេចក្តីត្រូវការគ្រឿងញៀន និងបញ្ចូលការបង្ការគ្រឿងញៀនផ្អែកលើភស្តុតាង និងការព្យាបាលអ្នកញៀនគ្រឿងញៀន។ កម្មវិធីនេះលើកកម្ពស់សេវាដែលផ្តល់កិច្ចគាំពារបន្តបន្ទាប់ពីការព្យាបាល សម្របតាមតម្រូវការរបស់អ្នកប្រើប្រាស់គ្រឿងញៀនមិនអាចអត់បាន នៅគ្រប់ដំណាក់កាលសង្គម ការព្យាបាល និងការជម្រុញលើកទឹកចិត្ត។

៨. នៅក្រោមឆ័ត្រទាំងមូលនៃកម្មវិធីរួមគ្នានេះ នៅឆ្នាំ២០០៨ អង្គការ UNODC បានចាប់ផ្តើមគម្រោងសកលមួយដែលមានឈ្មោះថា ទ្រីតណែត។ សមាសភាគតំបន់ដែលរាប់បញ្ចូលទាំងប្រទេសកម្ពុជា បានចាប់ផ្តើមនៅឆ្នាំ

២០០៩។ បេសកកម្មរបស់ទ្រីតណែត នៅអាស៊ីអាគ្នេយ៍ គឺដើម្បីបង្ហាញពីសេវាព្យាបាលមានប្រសិទ្ធភាពនៅតាមមូលដ្ឋានសហគមន៍ដល់អ្នកញៀនគ្រឿងញៀន។ កម្មវិធីនេះ នឹងបង្កើតកសាងបន្ថែមលើកិច្ចខិតខំប្រឹងប្រែងជាមុនគៀងគរសហគមន៍របស់អង្គការUNODC និងប្រើប្រាស់ជាមូលដ្ឋានសម្រាប់ ការគាំទ្រដែលមានការសម្របសម្រួលដ៏ធំរបស់អង្គការសហប្រជាជាតិ ដែលរំពឹងថានឹងត្រូវបានផ្តល់តាមរយៈសំណើមួយដែលកំពុងស្ថិតក្នុងការបង្កើត។

៩. រាជរដ្ឋាភិបាលកម្ពុជា (រ.រ.ក) បានស្នើសុំឲ្យ UNCT គាំទ្រការផ្តល់ជំនួយមនុស្សធម៌ ឬជំនួយសុខភាពដល់មណ្ឌលព្យាបាលជាកំហិត ហើយសំណើនោះ UNCT បានយល់ព្រម។ ការផ្តល់ជំនួយបែបនេះ ចាំបាច់ត្រូវតែស្របទៅនឹងការប្តេជ្ញាចិត្តមួយច្បាស់លាស់ ក្នុងនាមរាជរដ្ឋាភិបាលកម្ពុជា ដើម្បីគោរពតាមបទបញ្ញត្តិសិទ្ធិមនុស្សជាមូលដ្ឋាន ដូចមានចែងក្នុងរដ្ឋធម្មនុញ្ញ និងកាតព្វកិច្ចរបស់រាជរដ្ឋាភិបាលកម្ពុជា ក្រោមច្បាប់អន្តរជាតិ៖

ក. ធានាថាមិនមានការឃុំខ្លួនខុសច្បាប់ និងដោយបំពាន។

ខ. ធានាការគោរពបទដ្ឋានអប្បបរមានៃកិច្ចគាំពារបែបមនុស្សធម៌ និងការចៀសវាងការប្រព្រឹត្តអមនុស្សធម៌ និងបន្ថោកបន្ទាប

គ. ធានាថាការបង្ខាំងមនុស្សក្នុងមជ្ឈមណ្ឌលបន្សាបគ្រឿងញៀន ធ្វើទៅបានតាមគោលការណ៍ស្ម័គ្រចិត្ត ឬបើធ្វើដោយបង្ខំ ត្រូវមានសេចក្តីសម្រេចពីតុលាការ ហើយ

ឃ. ធានាថាមជ្ឈមណ្ឌលទាំងនេះ ត្រូវស្ថិតក្រោមការត្រួតពិនិត្យរបស់តុលាការ ហើយបើកឲ្យមានការតាមឃ្លាំមើល និងការធ្វើរបាយការណ៍ឯករាជ្យដទៃផ្សេងទៀត។

១០. UNCT ត្រូវបានគេប្រាប់ឲ្យដឹងអំពីគោលបំណងរបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការកាត់បន្ថយចំនួនមជ្ឈមណ្ឌលព្យាបាលជាកំហិតនៅឆ្នាំ២០១៥។ UNCT សូមស្វាគមន៍ការប្តូរទៅគំរូផ្អែកលើមូលដ្ឋានភស្តុតាង និង សហគមន៍ ស្របតាមវិធីសាស្រ្តផ្អែកលើមូលដ្ឋានសិទ្ធិ។ UNCT សង្ឃឹមថា ការកាត់បន្ថយចំនួនមជ្ឈមណ្ឌលនឹងឆ្លុះបញ្ចាំងតាមរយៈការកាត់បន្ថយយ៉ាងច្រើននៃចំនួនអតិថិជន នៅខណៈដែលពួកគេទទួលបានជាបន្តបន្ទាប់នូវសេវាពីប្រព័ន្ធព្យាបាលអ្នកញៀនគ្រឿងញៀនដែលមានមូលដ្ឋាននៅតាមសហគមន៍ដែលកំពុងអភិវឌ្ឍ ជាមួយនឹងបទដ្ឋានគាំពារស្របតាមការអនុវត្តល្អបំផុតជាអន្តរជាតិ ហើយដែលបានផ្សារភ្ជាប់ទៅនឹងកិច្ចអន្តរាគមន៍ចំនួន ប្រាំបួននៃកញ្ចប់កាត់បន្ថយគ្រោះថ្នាក់ដែលបានផ្តល់អនុសាសន៍ដោយអង្គការសហប្រជាជាតិ ដែលជាឱកាសមួយសម្រាប់កម្ពុជា ដើម្បីដឹកនាំផ្លូវសម្រាប់ប្រទេសដទៃផ្សេងទៀត។

១១. UNCT តបតាមសំណើរបស់រាជរដ្ឋាភិបាលកម្ពុជា បានឯកភាពយល់ព្រម បង្កើតសំណើមួយសម្រាប់ការផ្តល់សេវាព្យាបាលអ្នកញៀនគ្រឿងញៀនដែលមានមូលដ្ឋាននៅតាមសហគមន៍ នៅឃុំ/សង្កាត់ចំនួន ៣៥០ ក្នុងប្រទេស កម្ពុជា។

១២. UNCT បានកំពុងធ្វើការ ដើម្បីបង្កើតសំណើរមួយ ដោយរួមបញ្ចូលគំនិតផ្តួចផ្តើមមួយចំនួនដែលកំពុងបន្ត និងដែលបានគាំទ្រពីរាជរដ្ឋាភិបាលកម្ពុជា។ គំនិតផ្តួចផ្តើមទាំងនេះ រួមបញ្ចូល ៖

ក. សកម្មភាពផ្សព្វផ្សាយ និងណែនាំនៅតាមមូលដ្ឋានសហគមន៍ ដែលបានអនុវត្តសាកល្បងដោយគម្រោង H83 របស់អង្គការ UNODC ។

ខ. ការអនុវត្តនៅពេលដ៏ឆាប់ៗនេះ នូវគម្រោងសាកល្បងថៃទាំមេតាដុនដែលគាំទ្រដោយអង្គការសុខភាពពិភពលោក

គ. ការបង្ហាញពីសេវាកម្មតាមសហគមន៍ ដែលបានគ្រោងធ្វើតាមរយៈកម្មវិធី ទ្រីតណែតរបស់អង្គការ UNODC និង

ឃ. ការរៀបចំបង្កើតផែនការយុទ្ធសាស្ត្រសម្រាប់សុខភាពផ្លូវចិត្ត និងអន្តរាគមន៍ការប្រើប្រាស់សារធាតុញៀន។

១៣. នៅពេលដែលសំណើរនេះត្រូវបានសរសេរបញ្ចប់ និងអនុម័តយល់ព្រមដោយរាជរដ្ឋាភិបាលកម្ពុជាហើយនោះ គឺតម្រូវឲ្យមានការឆ្លើយតបរួមគ្នាមួយពីម្ចាស់ជំនួយ។

ចប់